ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ : ០១៧ រ.ដ.ក/រ.ដ.ប

ថ្ងៃសុក្រ ១៤កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩

នាយកដ្ឋានបណ្ដុះបណ្ដាល
ចូល លេខ 341 ម៉ោង 9-00
ថ្ងៃទី 15 ខែ 11 ឆ្នាំ 19
ហត្ថលេខា...............

# របាយការណ៍

## ស្តីពី

## សកម្មភាព និងលទ្ធផលការងារប្រចាំខែតុលា ឆ្នាំ២០១៩ និងទិសដៅការងារបន្តសម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានរដ្ឋបាល

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

ក្នុងខែតុលា ឆ្នាំ២០១៩នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ច ដោយសម្រេចលទ្ធផលបានដូចខាងក្រោម៖

### I-សកម្មភាពការងារ និងលទ្ធផល

#### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារ ដែលបញ្ជូនមកពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះ ក្រសួងមហាផ្ទៃ សរុបចំនួន ៥៦៥ច្បាប់ និងបានធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខេត្ត និងខេត្តចំនួន ២១៣ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៣៤ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១៧៩ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ២៨ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៤៤ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៧៨ច្បាប់។

-បានទទួលលិខិតមកពីនាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមានចំនួន៣៦៩ច្បាប់ ដែលក្នុងនោះមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខេត្ត និងខេត្តចំនួន ១២៧ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ១៦ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១១០ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ២១ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ២៩ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៦៦ច្បាប់ ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍ និងពិនិត្យសម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន២៥៨ច្បាប់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍និងពិនិត្យ សម្រេច ដែលក្នុងនោះឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខេត្ត និងខេត្តចំនួន ៨៥ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ០៦ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៩៣ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ១៤ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ១៥ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៤៥ច្បាប់។

-បានទទួលឯកសារចំនួន១៦៥ច្បាប់ ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះ ដើម្បីចាត់ចែងបន្តរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខេត្ត និងខេត្តចំនួន ៤០ច្បាប់

នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ០៦ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៦៥ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ១២ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ១៣ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ២៩ច្បាប់។

**២-ការងារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

ក្នុងខែតុលាឆ្នាំ២០១៩នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន ៧៦ច្បាប់ ក្នុងនោះ លិខិតបង្គាប់ការចំនួន ៣១ច្បាប់ និងលិខិតបញ្ជាបេសកកម្មចំនួន ៤៥ច្បាប់ ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្តនានា។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្តាខេត្ត ដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការងារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

ក្នុងខែតុលាឆ្នាំ២០១៩ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ សិក្ខាសាលា វេទិកា និងកម្មវិធីនានាដូចខាងក្រោម៖

-ចូលរួមជាមួយ**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តម **Masahiro MIKAMI** ឯកអគ្គរាជទូតជប៉ុន ទើបតែងតាំងថ្មីប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម

-ចូលរួមជាមួយ**ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ** ក្នុងឱកាសអនុញ្ញាតឱ្យលោកស្រី JhelumT.Thomas អ្នកជំនាញជាន់ខ្ពស់ នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធនឹងការរៀបចំសាលាជាតិរដ្ឋបាលមូលដ្ឋាន។

- ការប្រជុំ និងសិក្ខាសាលា៖

-ដឹកនាំកិច្ចប្រជុំគណៈកម្មការកំណែវិញ្ញាសា និងអនុគណៈកម្មការនានា ដើម្បីធ្វើកំណែវិញ្ញាសាប្រឡងជ្រើសរើសសិស្ស-និស្សិតបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០១៩

-ដឹកនាំកិច្ចប្រជុំពិភាក្សា លើសេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ និងសេចក្តីព្រាង សេចក្តីណែនាំស្តីពីការពង្រឹងដល់ការអនុវត្តនីតិវិធីនៃការរៀបចំ និងការអនុវត្តគម្រោងក្រុង ស្រុក

-ដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយលោក Yun.HyunCheol អនុព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជាពាក់ព័ន្ធនឹង ការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-កូរ៉េ ស្តីពីទីក្រុងឆ្លាត (Asean-Rok Ministerial Meeting on Smart City) នៅទីក្រុងប៊ូសាន នៃសាធារណរដ្ឋកូរ៉េ

-សហការជាមួយក្រុមការងារធនាគារពិភពលោក (World Bank) ដើម្បីរៀបចំកិច្ចប្រជុំជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំគម្រោងធ្វើឱ្យប្រសើរឡើង នូវការគ្រប់គ្រងសំណល់រឹង និងប្លាស្ទិក នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ចូលរួមកិច្ចប្រជុំជាមួយក្រុមការងាររបស់អង្គការតម្លាភាព ស្តីពីការរៀបចំរបាយការណ៍បន្ទាប់ពីការបណ្តុះបណ្តាលប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ៥២គោលដៅចាស់

-ចូលរួមកិច្ចប្រជុំក្រុមការងារដោះស្រាយដីបង្កស្ថិតក្នុងភូមិជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល សម្រាប់បម្រុងទុកសាងសង់អគារទីស្នាក់ការនិងហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារព្រំដែនអន្តរជាតិជ្រៃធំ សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីវិធានការណ៍ចាំបាច់នានាសម្រាប់សភាពការណ៍បច្ចុប្បន្ន

-ចូលរួមកិច្ចប្រជុំក្រុមការងាររបស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដោះស្រាយសំណើ សំណូមពររបស់អង្គការសង្គមស៊ីវិល ដើម្បីពិភាក្សាលើសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិលដែលប្រមូលបាននៅក្នុង

វេទិកាស្តីពីភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលលើកទី៣ ក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល

-ចូលរួមកិច្ចប្រជុំក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ វិសោធនកម្មច្បាប់ស្តីពីអន្តោប្រវេសន៍ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា

-ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការធ្វើវិសោធនកម្មមាត្រា ៤២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការពិនិត្យតារាងផលិតទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ នៅទីស្តីការក្រសួងផែនការ

-ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ នៅសាលប្រជុំទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

-ចូលរួមកិច្ចប្រជុំលើកទី៣ នៃគណៈកម្មការរៀបចំមហាសន្និបាតរបស់សមាគមអន្តរជាតិ នៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង (AIMF) លើកទី៣៩ ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ នៅសាលប្រជុំសាលារាជធានីភ្នំពេញ

-ចូលរួមកិច្ចប្រជុំស្តីការរៀបចំកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌដែលរៀបចំឡើយដោយលេខាធិការដ្ឋាន គ.ជ.អ.ប នៅរដ្ឋបាលខណ្ឌគោលដៅចំនួន២ គឺនៅខណ្ឌពោធិ៍សែនជ័យ និងខណ្ឌដូនពេញ

-ចូលរួមកិច្ចប្រជុំជាមួយតំណាងអង្គការអភិវឌ្ឍសហគ្រាសទឹក និងអនាម័យហៅកាត់ (វ័តជើសេដ) ដើម្បីពិភាក្សាលើកិច្ចសហការនាពេលអនាគត

-ចូលរួមកិច្ចប្រជុំអន្តរក្រសួងដើម្បីណែនាំពីការផ្តល់ធាតុចូល និងទិន្នន័យសម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ២០១៦-២០៣០ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ រៀបចំដោយក្រសួងផែនការ

-ចូលរួមជាអធិបតីបើកកិច្ចប្រជុំពិភាក្សារៀបចំផែនការសកម្មភាព-និងថវិកា ឆ្នាំ២០២០ របស់គម្រោង LEAP

-ចូលរួមកិច្ចប្រជុំពិភាក្សាអំពីការធ្វើអាទិភាវូបនីយកម្មការងារដែលនៅសេសសល់សម្រាប់តំបន់រដ្ឋបាលខេត្តស្រុងឃុំ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ស្តីពីសេចក្តីព្រាងអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក

-ចូលរួមកិច្ចប្រជុំស្តីពីសេចក្តីព្រាងផែនការយុទ្ធសាស្ត្ររយៈពេល០៥ឆ្នាំ (២០១៩-២០២៣) របស់អគ្គស្នងការ-ដ្ឋាននគរបាលជាតិ

-ចូលរួមកិច្ចប្រជុំពិភាក្សាបញ្ចប់ការធ្វើប្រតិកូកម្មមុខងារ និងបញ្ចប់លើការរៀបចំទម្រង់ពាក្យស្នើសុំបែបបទនីតិវិធី ព្រមទាំងលក្ខខណ្ឌភ្ជាប់នានា សម្រាប់ការផ្តល់សេវារដ្ឋបាលលើវិស័យកសិកម្ម នៅអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យច្រកចេញចូលតែមួយ

-ចូលរួមកិច្ចប្រជុំជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នា នៃប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ICRG-JG) នៃក្រុមការងារហិរញ្ញវត្ថុ(FATF)

-ចូលរួមកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីបន្តពិភាក្សា និងឆ្លងកំណត់ហេតុវាយតម្លៃការស្នើសុំដោះដូរទីតាំងពន្ធនាគារខេត្តកំពង់ឆ្នាំង នៅសាលាខេត្តកំពង់ឆ្នាំង

-ចូលរួមកិច្ចប្រជុំ ដើម្បីពិនិត្យ ពិភាក្សា លើការផ្ទេរមុខងារ និងការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង របស់រដ្ឋបាលខណ្ឌ នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការប្រើប្រាស់ និងការការពាររបង្គំរូបកាកបាទក្រហម នៅសណ្ឋាគារកាំបូឌីយ៉ាណា

-ចូលរួមកិច្ចប្រជុំពិនិត្យ និងវាយតម្លៃ ទីតាំងដីអតីតកាស៊ីណូ ទំហំ១១.៩២៥ម៉ែត្រការ៉េ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តកែប ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ និងកងកម្លាំងប្រដាប់អាវុធ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកែប

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើស និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

-ចូលរួមសិក្ខាសាលាស្តីពីការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការរីកសាយភាយហិរញ្ញប្បទានអាវុធមហាប្រល័យ

-ចូលរួមសិក្ខាសាលាស្តីពី"កំណែទម្រង់រដ្ឋបាលសាធារណៈក្នុងបរិបទកម្ពុជានិងអន្តរជាតិ" នៅសាលាភូមិន្ទរដ្ឋបាល

-ចូលរួមសិក្ខាសាលាស្តីពី"ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកិច្ចបញ្ជិកាសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ" នៅខេត្តកែប

-ចូលរួមសិក្ខាសាលាស្តីពីរបកគំហើញលើលទ្ធភាពបញ្ជ្រាបការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការសិក្សាជាមូលដ្ឋាន លើយន្តការសម្របសម្រួលកិច្ចការពារកុមារដែលមានស្រាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

-ចូលរួមសិក្ខាសាលាតម្រង់ទិសអំពីគំរូនៃការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជនក្រុង ស្រុក នៅខេត្តកំពង់ចាម

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍ និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពី "ការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត" នៅសណ្ឋាគារសុខាភ្នំពេញ រៀបចំដោយក្រសួងរ៉ែ និងថាមពល

-ចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពីក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី «នាមភូមិសាស្ត្រ និងការប្រើប្រាស់នៅកម្ពុជា» ដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

▪ **កម្មវិធីផ្សេងៗ៖**

-ចូលរួមក្នុងពិធីប្រកាសចូលកាន់មុខតំណែងអភិបាលរង នៃគណៈអភិបាលខេត្តស្វាយរៀង

-ចូលរួមអមដំណើរ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ទៅបំពេញទស្សនកិច្ចសិក្សានៅប្រទេសអាល្លឺម៉ង់

-ចូលរួមមហាសន្និបាតអាណត្តិទី២ របស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត

-ចូលរួមគោរពវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ (ព្រះបរមរតនកោដ្ឋ)

-ចូលរួមកម្មវិធីជជែកពិភាក្សា ស្តីពីយន្តការនៃការការពារកុមារថ្នាក់ក្រោមជាតិ

-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុងស្រុក ឃុំ សង្កាត់ នៅខេត្តកំពង់ចាម

-ចូលរួមវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិស្តីពីសៀវភៅប្រតិបត្តិគោល និងប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនមន្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ២ឆ្នាំក្នុងគ្រួសារក្រីក្រ

-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់មន្ត្រីជាន់ខ្ពស់ (National Governmental Administration for Senior Official) នៅប្រទេសជប៉ុន

-ចូលរួមក្នុងកម្មវិធីបើកយុទ្ធនាការបណ្តុះបណ្តាល និងផ្សព្វផ្សាយស្តីពី បច្ចេកទេសជួសជុលថែទាំផ្លូវថ្នល់ និងការប្រើប្រាស់កម្មវិធីថែទាំផ្លូវ Road Care Mobile App របស់ក្រសួងសាធារណការ និងដឹកជញ្ជូនដែលរៀបចំដោយក្រសួងសាធារណការ។

### ៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

#### ៤.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង

##### ៤.១.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន

សេចក្តីណែនាំលេខ ០៣៧ ចុះថ្ងៃ០៣ ខែតុលា ឆ្នាំ២០១៩ ស្តីពីនីតិវិធី នៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។

##### ៤.១.១-លិខិតបទដ្ឋានគតិយុត្តដែលកំពុងរៀបចំ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

-សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធីកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សា នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី «កិច្ចការរដ្ឋបាល» សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា (ផ្នែករដ្ឋបាលស៊ីវិល)ចំណុះទីស្តីការក្រសួងមហាផ្ទៃ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- សេចក្តីព្រាងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ វាយតម្លៃ លើផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

#### ៤.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ

##### ៤.២.១-លិខិតបទដ្ឋានគតិយុត្តកំពុងសហការរៀបចំ

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការបែងចែកចំណូល ដែលបានមកពីការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោមពីរឆ្នាំ ក្នុងគ្រួសារក្រីក្រ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង

- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការបែងចែកចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០២៨។

## ៥-ការងារបុគ្គលិក

### ៥.១-ការងារក្របខ័ណ្ឌ

គិតត្រឹមខែតុលា ឆ្នាំ២០១៩ ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសរុបមានចំនួន ១៣.២៨២រូប/ស្រី ៣.៣៥០រូប (ក្នុងនោះក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៩៧០រូប/ស្រី២៣១រូប ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន ៩.១៦៣រូប/ស្រី ២.៦៥២រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន ១.១៨៥រូប/ស្រី ១៨៧រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន ១.៩៦៤រូប/ស្រី ២៨០រូប) បើប្រៀបធៀបទៅនឹងខែកញ្ញា ឆ្នាំ២០១៩ ក្របខ័ណ្ឌថយចុះចំនួន ០៣រូប/ស្រី ០១រូប។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលដែលបានផ្ទេរចូលពីក្របខ័ណ្ឌក្រសួងនានាចំនួន ០៧រូប/ស្រី០១រូប និងផ្ទេរក្របខ័ណ្ឌចេញពីក្រសួងចំនួន ១០រូប/ស្រី០២រូប (ក្នុងនោះផ្ទេរទៅក្នុងក្របខ័ណ្ឌក្រសួងនានាចំនួន ០៦រូប/ស្រី ០១រូប លុបឈ្មោះដោយមរណភាពចំនួន ០២រូប/ស្រី ០១រូប និងលុបឈ្មោះដោយហួសកំណត់បន្ទាប់ពីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន០២រូប។

### ៥.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល

ក្នុងខែតុលា ឆ្នាំ២០១៩នេះ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីរាជការឈប់សម្រាកពីការងារសរុបចំនួន ០៨រូប/ស្រី០៧ (ក្នុងនោះសម្រាកលំហែមាតុភាពចំនួន ០៦រូប និងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ០២រូប/ស្រី ០១រូប) ។ ទន្ទឹមនោះថ្នាក់ដឹកនាំក្រសួង ក៏បានផ្តល់គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ២៤៩គ្រឿង(ក្នុងនោះគ្រឿងឥស្សរិយយសជាតូបការចំនួន ០៣គ្រឿង គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ចំនួន ១១៥គ្រឿង រួមមាន ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន ០៦គ្រឿង ថ្នាក់មហាសេនាចំនួន ១៣គ្រឿង ថ្នាក់ធិបឌិន្ទចំនួន ១៨គ្រឿង ថ្នាក់សេនាចំនួន ៣១គ្រឿង និងថ្នាក់អស្សឫទ្ធចំនួន ៤៧គ្រឿង និងមេដាយការងារតាមលំដាប់ថ្នាក់ចំនួន ១៣១គ្រឿង រួមមាន ថ្នាក់មាសចំនួន ៤៦គ្រឿង ថ្នាក់ប្រាក់ចំនួន ៥៤គ្រឿង ថ្នាក់សំរិទ្ធិចំនួន ៣១គ្រឿង) និងបានផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិលចំនួន៦៤ប័ណ្ណ/ស្រី១១ប័ណ្ណ(ក្នុងនោះមន្ត្រីរដ្ឋបាលជាន់ខ្ពស់ចំនួន ៣៨ ប័ណ្ណ/ស្រី០៥រូប មន្ត្រីក្រមការចំនួន ២០ប័ណ្ណ/ស្រី០៦រូប លេខាធិការរដ្ឋបាលចំនួន ០៦ប័ណ្ណ។

### ៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ

ស្ថានភាពបច្ចុប្បន្នភាព នៃចំនួនមន្ត្រីរាជការស៊ីវិលតាមមុខតំណែង ដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃសរុបចំនួន ៩៧០រូប/ស្រី ២៣១រូប ស្មើនឹង ២៣.៨១% ដែលក្នុងនោះរួមមាន ៖

-មន្ត្រីរាជការស៊ីវិលចំនួន ៩៤២រូប/ស្រី ២២៤រូប ស្មើនឹង ២៣.៩៩% ក្នុងនោះរួមមាន (រដ្ឋលេខាធិការចំនួន ០៣រូប អនុរដ្ឋលេខាធិការចំនួន ០៤រូប/ស្រី ០១រូប អគ្គនាយកចំនួន ០១រូប អគ្គនាយករងចំនួន ២៣រូប/ស្រី ០២រូប អគ្គលេខាធិការរងចំនួន ០៤រូប/ស្រី ០១រូប លេខាធិការ គជបទ ចំនួន ០៣រូបរួមមាន (ប្រធាន ០១រូប អនុប្រធាន ០១រូប និងសមាជិកចំនួន០១រូប) ក្រុមប្រឹក្សានីតិកម្មចំនួន ០៧រូប/ស្រី០២រូប (ក្នុងនោះប្រធានចំនួន ០១រូប អនុប្រធានចំនួន ០៣រូប/ស្រី០១រូប សមាជិកចំនួន ០៣រូប/ស្រី០១រូប) លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ

សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគ.ជ.អ.ប ចំនួន ១៧រូប/ស្រី ០៦រូប អគ្គាធិការ ចំនួន ០១រូប អគ្គាធិការរងចំនួន ០៩រូប/ស្រី០១រូប ប្រធាននាយកដ្ឋានចំនួន១៥រូប អនុប្រធាននាយកដ្ឋាន ចំនួន ១៦២រូប/ស្រី៣០រូប ប្រធានការិយាល័យចំនួន ៨៥រូប/ស្រី១៧រូប អនុប្រធានការិយាល័យចំនួន ២៣៩រូប/ស្រី៦៩រូប និងមន្ត្រីចំនួន ៣៦៩រូប/ស្រី៩៥រូប។

-មន្ត្រីដែលផ្ទេរភារកិច្ចពីថ្នាក់ក្រោមជាតិមកទីស្តីការក្រសួងចំនួន ១៧រូប/ស្រី០១រូប ស្មើនឹង១៥%

-មន្ត្រីរាជការក្របខណ្ឌដែលមានមុខតំណែងជាទីប្រឹក្សា និងជំនួយការចំនួន ១៨៦រូប/ស្រី ១៨រូប ស្មើនឹង៧,៥៦%

ក្នុងខែតុលា ឆ្នាំ២០១៩នេះ ក្រសួងមហាផ្ទៃបានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្ទេរភារកិច្ច ផ្លាស់ប្តូរភារកិច្ច និងលុបឈ្មោះជូនមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិសរុបចំនួន ១៨រូប/ស្រី០១រូប។

**៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

គិតត្រឹមខែតុលា ឆ្នាំ២០១៩ ស្ថានភាពបច្ចុប្បន្នភាពនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសមានដូចខាងក្រោម ៖

-គណៈអភិបាលរាជធានី ខេត្តសរុបចំនួន១៧៥រូប/ស្រី២៧រូប ស្មើនឹង១៥,៤២% ក្នុងនោះ(អភិបាលរាជធានី ខេត្តចំនួន ២៥រូប/ស្រី០១រូប អភិបាលរងរាជធានី ខេត្តចំនួន ១៥០រូប/ស្រី២៦រូប)

-គណៈអភិបាលក្រុង ស្រុក ខណ្ឌសរុបចំនួន៩៣៨រូប/ស្រី១៩៨រូប ស្មើនឹង២១,១១% ក្នុងនោះ(អភិបាលក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី ០៧រូប អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន ៧៣៥រូប/ស្រី ១៩១រូប)

-មន្ត្រីស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន ៦.៥២១រូប/ស្រី ២.១៦៥រូប ស្មើនឹង ៣៣,២% ក្នុងនោះ (សាលារាជធានី ខេត្តចំនួន ២.៨០៩រូប /ស្រី៩១៤រូប ស្មើនឹង៣២,៥៤% សាលាក្រុង ស្រុក ខណ្ឌចំនួន ៣.៧១២រូប/ស្រី ១.២៥១រូប ស្មើនឹង ៣២,៥៤%) និងប្រធានទីស្នាក់ការច្រកទ្វារព្រំដែនចំនួន ៥៤រូប។ ក្នុងខែតុលា ២០១៩នេះ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានពិនិត្យ សម្រេចតែងតាំងមុខតំណែង ផ្ទេរភារកិច្ចអភិបាល អភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាល និងការផ្លាស់ប្តូរ តែងតាំងស្មៀនឃុំ សង្កាត់សរុបចំនួន៥០រូប/ស្រី ០៦រូប(ដូចក្នុងឧបសម្ព័ន្ធ១ក-១គ)។

**៥.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ស្ថានភាពបច្ចុប្បន្នភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន ៥៥៩រូប/ស្រី៩៥រូប (ស្មើនឹង១៦.៩៩%) ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន ២៥រូប សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន ៥៣៤រូប/ស្រី ៩៥រូប)។

-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៥៥៥រូប/ស្រី៦២៤រូប (ស្មើនឹង១៨.៣៩%)ក្នុងនោះ: ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៥រូប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន៣.៣៥២រូប/ស្រី៦១៩រូប។

សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន ១១.៥៧២រូប/ស្រី២.៣៩០រូប(ស្មើនឹង២០,៦៥%) (ក្នុងនោះ មេឃុំ ១.៤១០រូប/ស្រី១០៧រូប ចៅសង្កាត់ចំនួន ២៣៦រូប/ស្រី២៦រូប ជំទប់ទី១ចំនួន ១.៤១០រូប /ស្រី២២៨រូប ជំទប់ទី២ចំនួន ១.៤១០ រូប/ស្រី៣០៤រូប ចៅសង្កាត់រងទី១ ចំនួន ២៣៦រូប/ស្រី ៦០រូប ចៅសង្កាត់រងទី២ ចំនួន២៣៦រូប/ស្រី៥២រូប និងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ចំនួន ៦.៦៣៤រូប/ស្រី១.៦១៣រូប)។ ក្នុងខែតុលា ឆ្នាំ២០១៩នេះ ការផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់សរុបចំនួន១៨រូប/ស្រី០១រូប ក្នុងនោះសមាសភាពក្រុមប្រឹក្សារាជធានីខេត្តចំនួន ០២រូប(ដូចក្នុងឧបសម្ព័ន្ធ ២ក) សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន០៦រូប/ ស្រី០១រូប (ដូចក្នុងឧបសម្ព័ន្ធ ២ខ) និងសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន១០រូប(ដូចក្នុងឧបសម្ព័ន្ធ២គ)។

## ៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល

ស្ថានភាពបច្ចុប្បន្នភាព នៃចំនួនប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលប្រវត្តិរូបក្នុងប្រព័ន្ធទិន្នន័យសរុបចំនួន ៩.៧៧៧រូប/ស្រី២.៧៤១រូប(ក្នុងនោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៨៩០រូប/ស្រី២០១រូប និងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិចំនួន ៨.៨៨៧រូប/ស្រី ២.៥៤១រូប)។ ក្នុងខែតុលា ឆ្នាំ២០១៩នេះ ផ្នែកបញ្ចូលនឹងគ្រប់គ្រងទិន្នន័យបានធ្វើបច្ចុប្បន្នភាពរួចរាល់ចំពោះគណៈអភិបាលខេត្ត ក្រុង ស្រុកចំនួន ០៣ខេត្ត គឺខេត្តបាត់ដំបង ខេត្តកំពង់ចាម និងខេត្តបន្ទាយមានជ័យ។

## ៦-ការងារអភិវឌ្ឍន៍សមត្ថភាព

### ៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស

ក្នុងខែតុលា ឆ្នាំ២០១៩នេះ ក្រសួងមហាផ្ទៃបានសហការរៀបចំ និងរៀបចំវគ្គបណ្តុះបណ្តាលចំនួន០៥វគ្គ និងមានសិក្ខាកាមសរុបចំនួន ១៨៦រូប/ស្រី ៧៣រូប ដូចខាងក្រោម៖

-វគ្គបណ្តុះបណ្តាលវិស្វករ IT កម្រិត១ (IT Passport)នៅវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT)មានសិក្ខាកាមចូលរួមចំនួន០២រូប

-វគ្គវិក្រឹត្យការមូលដ្ឋានសម្រាប់ក្រុមគោលដៅជាប្រធាន និងឬអនុប្រធានការិយាល័យនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានរយៈពេលសរុបចំនួន២៤០ម៉ោង នៅស្ពេស៊ាណេត ឯ.ក(SpaciaNet Co., Ltd.)រាជធានីភ្នំពេញ ដែលមានសិក្ខាកាមចូលរួមចំនួន ៣០រូប/ស្រី០៧រូប

-វគ្គភាពជាអ្នកដឹកនាំជាស្ត្រីសម្រាប់ក្រុមគោលដៅជាអភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌជាស្ត្រី នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)រាជធានីភ្នំពេញ ដែលមានសិក្ខាកាមចូលរួមចំនួន ៣០រូប/ស្រី៣០រូប

-វគ្គបណ្តុះបណ្តាលវិក្រឹត្យការជំនាញ ស្តីពី" ព័ត៌មានវិទ្យាសម្រាប់ការិយាល័យ " នៅសាលបណ្តុះបណ្តាលអគារទីស្តីការក្រសួងមហាផ្ទៃដែលមានសិក្ខាកាមចូលរួមចំនួន ៨០រូប/ស្រី២៦រូប

-បានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសមភាពយេនឌ័រក្នុងការផ្តល់សេវាសាធារណៈនៅទីស្តីការក្រសួងមហាផ្ទៃ ដែលមានសិក្ខាកាមចូលរួមចំនួន ៤៤រូប/ស្រី១០រូប។

ទន្ទឹមនោះ អគ្គនាយកដ្ឋានរដ្ឋបាល បាន និងកំពុងរៀបចំចងក្រងឯកសារសម្រាប់បណ្តុះបណ្តាលដូចខាងក្រោម៖

-បាន និងកំពុងរៀបចំសៀវភៅមេរៀនសម្រាប់វគ្គវិក្រឹត្យការមូលដ្ឋាន

-បាន និងកំពុងចងក្រងទិន្នន័យអភិវឌ្ឍន៍សមត្ថភាព

-បាន និងកំពុងរៀបចំឯកសារមេរៀនសម្រាប់វគ្គវិក្រឹត្យការមូលដ្ឋាន សម្រាប់ក្រុមគោលដៅជាមន្ត្រីទីស្តីការក្រសួងមហាផ្ទៃ

-បាន និងកំពុងគ្រោងរៀបចំវគ្គបណ្តុះបណ្តាលស្មៀនថ្មីទើបប្រឡងជាប់ក្របខណ្ឌឆ្នាំ២០១៩។

### ៦.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន

ក្នុងខែតុលា ឆ្នាំ២០១៩នេះ ក្រសួងមហាផ្ទៃបានចាត់បញ្ជូនមន្ត្រីចំន ១១រូប /ស្រី០៥រូប ដើម្បីចូលរួមវេទិកាអ្នកដឹកនាំថ្នាក់តំបន់លើកទី២៥ ឆ្នាំ២០១៩ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី និងបានស្នើសុំលិខិតឆ្លងដែនផ្លូវការ និងការទូតសរុបចំនួន ០៨ច្បាប់ ក្នុងនោះ៖ លិខិតឆ្លងដែនផ្លូវការចំនួន ០៧ច្បាប់ និងលិខិតឆ្លងដែនការទូតចំនួន ០១ច្បាប់ ជូនអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ដើម្បីសម្រួលដល់ការធ្វើដំណើរចេញ ចូល ឆ្លងកាត់ព្រំដែន និងបំពេញបេសកកម្មក្រៅប្រទេស។

### ៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ

ចំពោះការងារព័ត៌មាននិងផ្សព្វផ្សាយ អគ្គនាយកដ្ឋានរដ្ឋបាលបាន និងកំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រមជ្ឈការនិងវិសហមជ្ឈការលេខ ០៤ និងបានបន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដោយបានបញ្ចូលអត្ថបទចំនួន ១៦ករណី ,រៀបចំចងក្រងឯកសារដើម្បីបង្ហោះឯកសារក្នុង Telegram Channel របស់អគ្គនាយកដ្ឋានរដ្ឋបាល និងបានផ្សព្វផ្សាយអាហារូបករណ៍ស្តីពីអាហារូបករណ៍ក្រោមកម្មវិធី"អ្នកដឹកនាំវ័យក្មេងសម្រាប់ឆ្នាំសិក្សា២០២០ នៅប្រទេសជប៉ុនផងដែរ។

## ៧-ការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

### ៧.១-ការគាំទ្របច្ចេកទេស និងអន្តរាគមន៍

ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃជម្រាបទៅក្រសួងស្ថាប័ន និង បានដាក់ចេញនូវគោលការណ៍ណែនាំដល់រដ្ឋបាលរាជធានី ខេត្តដូចខាងក្រោម៖

-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ករណីស្នើសុំផ្តល់ និងពន្យារលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីរាជការខេត្តកោះកុង ចំនួន១២រូប ដើម្បីទៅចូលរួមវេទិកា PNLG ប្រចាំឆ្នាំ២០១៩ នៅសាធារណរដ្ឋប្រជាមានិតចិន។

-រដ្ឋបាលរាជធានីភ្នំពេញ ករណីឈ្មោះ ហ៊ីង សុគន្ធីរ៉ា និងម៉េង លីដា ស្នើសុំអន្តរាគមន៍ឱ្យចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ អង្កេតដី និងកែតម្រូវប័ណ្ណកម្មសិទ្ធិលេខ ១២០០៦០៦-១៤៧៤ ទំហំ ១០ម៉ែត្រ x ១៥ម៉ែត្រ ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធិសារជាថ្មី ស្ថិតនៅភូមិរបោះអង្កាញ់ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

-រដ្ឋបាលខេត្តកណ្តាល ករណីឈ្មោះម៉េង ថុង ស្នើសុំអន្តរាគមន៍ទៅអាជ្ញាធរខេត្តកណ្តាលដែលអសកម្មមិនបានចាត់វិធានការផ្លូវច្បាប់ទៅលើសំណង់ខុសច្បាប់របស់លោក ស៊ុយ ស៊ីហ្ស រំលោភដីចំណីផ្លូវលេខ៨ និងគ្មានលិខិតអនុញ្ញាត ស្ថិតនៅភូមិអន្លង់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

-រដ្ឋបាលខេត្តកំពង់ឆ្នាំង ករណីសំណើសុំបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសហការជាមួយរដ្ឋបាលខេត្តកំពង់ឆ្នាំង ដោះស្រាយផលប៉ះពាល់សម្រាប់គម្រោងរៀបចំ កែលម្អ និងអភិវឌ្ឍន៍ច្រាំងទន្លេនៃក្រុងកំពង់ឆ្នាំង។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណីគណបក្សកសិករ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាល ដើម្បីឱ្យអាជ្ញាធរក្រុងប៉ោយប៉ែតជួយពិនិត្យសើរើឯកសារឡើងវិញ ដែលឈ្មោះ នួន យ៉ាន និង នួន យិប ភេទប្រុស បានលួចក្លែងបន្លំឯកសារសាធារណៈ និងរំលោភយកដីកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ នួន ស្រី ដែលមានទីតាំងស្ថិតនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

-រដ្ឋបាលខេត្តប៉ៃលិន ករណីការបញ្ចប់កិច្ចសន្យាស្តីពី ការអភិវឌ្ឍស្ទឹងប៉ៃលិនរមណីយដ្ឋានធម្មជាតិ រវាងរដ្ឋបាលខេត្តប៉ៃលិន ជាមួយក្រុមហ៊ុន ដេខាសលប្ប និងក្រុមហ៊ុន ប្រាជ៏អ៊ីនវេសមិនគ្រុប ឯ.ក។

-រដ្ឋបាលខេត្តកោះកុង រៀបចំពិព័រណ៍ពាណិជ្ជកម្មនៅក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដើម្បីអបអរសាទរពិធីបុណ្យកាន់បិណ្ឌភ្ជុំបិណ្ឌ ឆ្នាំ២០១៩។

-រដ្ឋបាលខេត្តព្រះសីហនុ ករណី៖

• ស្តីពីការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីទំហំ ៥៧០ហិកតា មកឱ្យឈ្មោះ លី សេងយាង ,ចាន់ ដានី, និងឈ្មោះម៉េង លីដា និងចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង និងកំណត់ព្រំដីជាក់ស្តែង ស្ថិតនៅភូមិអូរតាសេក ភូមិអូរឧកញ៉ាហេង និងភូមិអូរតាប៉ោង ឃុំអូរឧកញ៉ាហេង ភូមិស្ទាច់ដែង ឃុំរាម និងឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

• សំណើអញ្ជើញអភិបាលខេត្តព្រះសីហនុ ចូលរួមកិច្ចប្រជុំពិនិត្យគម្រោងប្លង់ស្ថាបនាផ្លូវក្រុងក្នុងខេត្តព្រះសីហនុ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

• សំណើសុំចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំងវាស់វែង និងកំណត់ព្រំដីជាក់ស្តែងទំហំ២១ហិកតា ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធិ ស្ថិតនៅភូមិស្រែចាមលើ និងភូមិកោះខ្យង ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

• ឈ្មោះ ឆាត់ ធុន, អ៊ុក សុភាព, លឹម សំអឿន និងង៉ូវ កឿន ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុពន្លឿនការអនុវត្តស្មារតីលិខិតលេខ ០៨៥/១៨លបក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តព្រះសីហនុ ដើម្បីចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង និងកំណត់ព្រំដី ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

• ឈ្មោះ កែម មង្គល និងមាស សាងមដានី ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ឱ្យចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ និងអង្កេតដីទំហំ ៤៦០ហិកតា ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធិដី ស្ថិតនៅភូមិអូរតាសេក ភូមិអូរឧកញ៉ាហេង និងភូមិអូរតាប៉ាង ឃុំអូរឧកញ៉ាហេង និងឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

• ពន្លឿនលិខិតលេខ ៦២/១៧ សជណ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពីការចេញប័ណ្ណកម្មសិទ្ធិលើផ្ទៃដីទំហំ ៤ហិកតា ៩៣អា ៣៦សង្ទីអា ស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ

-អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ករណីស្នើសុំអញ្ជើញនាយករដ្ឋបាល និងអ្នកនាំពាក្យរដ្ឋបាលរាជធានី-ខេត្ត ចូលរួមសិក្ខាសាលាស្តីពី "អភិបាលកិច្ចល្អនៅក្នុងបរិបទលំហូរព័ត៌មាននាយុគសម័យបច្ចេកវិជ្ជាឌីជីថល" នៅអគារមិត្តភាពទីស្តីការគណៈរដ្ឋមន្ត្រី។

-ក្រុមហ៊ុន ស្មាត អាស្យាតា ខូអិលធីឌី និងក្រុមហ៊ុន អ៊ីជតខូ (ខេមបូឌា) ខូអិលធីឌី ករណីស្នើសុំអន្តរាគមន៍ទៅអាជ្ញាធរមូលដ្ឋានជួយសម្របសម្រួលប្រជាពលរដ្ឋ ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនបានសាងសង់ និងដំឡើងបង្គោលអង់តែនទូរស័ព្ទ។

-ក្រុមហ៊ុន ដំរីមាស ឯ.ក ករណីស្នើសុំដាក់ដំណើរការអាជីវកម្មឆ្នោតរបស់ក្រុមហ៊ុន ដំរីមាស ឯ.ក នៅរាជធានីខេត្ត ទូទាំងប្រទេស។

-បានចាត់មន្ត្រីចុះធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលបានចំនួន ០៣ខេត្ត រួមមាន៖ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តសៀមរាប កាលពីថ្ងៃទី០៣ ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានធ្វើរបាយការណ៍បូកសរុបអំពី ៖

• ការចុះស្រាវជ្រាវប្រមូលព័ត៌មានទាក់ទងនឹងបទល្មើសព្រៃឈើក្នុងតំបន់ព្រៃឡង់ ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ។

• ស្ថានភាពទឹកជំនន់ទឹកភ្លៀងក្នុងភូមិសាស្ត្រខេត្តកំពង់ចាម ខេត្តបាត់ដំបង និងខេត្តស្ទឹងត្រែង។

• ករណីប្រតិកូលគណបក្សឆន្ទៈខ្មែរ ពាក់ព័ន្ធនឹងករណីវិវាទដីធ្លី ស្ថិតក្នុងភូមិសាស្ត្រខេត្តរតនគិរី។

• ករណីអគ្គិភ័យឆាបឆេះលំនៅឋានរបស់ប្រជាពលរដ្ឋនៅផ្សារដារ ភូមិដារផ្សារ ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

• ប្រជាពលរដ្ឋអនាមិកប្តឹងលោក កែវ វ៉ាន្នី ប្រធានសាខាគយ និងរដ្ឋាករខេត្តតាកែវ។

• លទ្ធផលកិច្ចប្រជុំពិភាក្សាអំពីករណីសំណើសុំអន្តរាគមន៍ ដើម្បីទប់ស្កាត់អភិបាលខេត្តកោះកុង កុំឱ្យផ្តល់ដីដែលត្រូវរាតបាប់យកដោយខុសច្បាប់ ក្នុងតំបន់ការពារធម្មជាតិ ស្ថិតនៅភូមិព្រះអង្គកែវ ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង។

### ៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត២៤ ក្រុង២៧ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១.៤០៥ សង្កាត់២៤១ និងភូមិចំនួន ១៤.៣៨៣។

### ៧.៣-ការងារផ្តល់គោរម្យងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ

ក្រសួងមហាផ្ទៃ បានលើកសំណើជូនរាជរដ្ឋាភិបាលកម្ពុជា ករណីស្នើសុំគោរម្យងារជាឧកញ៉ាចំនួន ០៣រូប **មេដាយមុនីសារាភ័ណ្ឌចំនួន ១៩គ្រឿង** (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៨គ្រឿង ថ្នាក់មហាសេនាចំនួន ០៧គ្រឿង និងថ្នាក់ធិបឌិន្ទចំនួន ០៤គ្រឿង) និងមេដាយមាសស្ថាបនាជាតិចំនួន ០៤គ្រឿង ដើម្បីផ្តល់ជូនសប្បុរសជន ដែលបានជួយកសាងសមិទ្ធផលជាច្រើននៅខេត្តកណ្តាល ខេត្តស្វាយរៀង និងខេត្តព្រៃវែងដោយចំណាយអស់ថវិកាសរុបចំនួន ៤.៧៣៩.៨៤៦ដុល្លារ(បួនលានប្រាំពីររយសាមសិបប្រាំបួនពាន់ប្រាំបីរយសែសិបប្រាំមួយដុល្លារសហរដ្ឋអាមេរិក) (ដូចក្នុងឧបសម្ព័ន្ធ ៣)។

### ៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា

#### ៧.៤.១-កម្មវិធីគាំទ្រដោយអង្គការសហប្រជាជាតិសម្រាប់កុមារ UNICEF

-បានប្រជុំពិភាក្សាអំពីសូចនាករវាយតម្លៃថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ នៃប្រព័ន្ធលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយទីប្រឹក្សា និងអង្គការយូនីសេហ្វ។

-បានប្រជុំជាមួយដៃគូ និងទីប្រឹក្សាអំពីការងារពិនិត្យ កែសម្រួលតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

-បានប្រជុំជាមួយដៃគូ និងទីប្រឹក្សា អំពីការងារជំរុញការចូលរួមរបស់យុវជនក្នុងការរៀបចំផែនការ និងថវិកាឃុំ សង្កាត់។

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលសៀវភៅណែនាំស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍សម្រាប់ឃុំ សង្កាត់ ដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ធំ។

### ៧.៤.២-គម្រោងសាងសង់អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP

គិតត្រឹមខែតុលា ឆ្នាំ២០១៩ ការវិវឌ្ឍនៃដំណើរការការដ្ឋានសាងសង់អគាររដ្ឋបាលស្រុក និងឃុំ សង្កាត់ គិតជារួមបានប្រមាណ២១% ក្នុងនោះដំណាក់កាលទី១ បាន៣៧% ដំណាក់កាលទី២ បាន២៦.៥% និងដំណាក់កាលទី៣ បាន០%។ ទន្ទឹមនឹងនេះ គិតត្រឹមខែតុលា ឆ្នាំ២០១៩ អគ្គនាយកដ្ឋានរដ្ឋបាលក៏បាន៖

-តាមដាន និងសម្របសម្រួលទាក់ទង និងសំណើសុំថវិកាបន្ថែមទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរក្សាការសាងសងអគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់តាមចំនួនដែលបានគ្រោងទុក។

-ចុះពិនិត្យតាមដានដំណើរការសាងសង់អគារសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ដំណាក់កាលទី១ និងទី២។

## ៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់

### ៧.៥.១-គម្រោងមូលនិធិក្រុង ស្រុក

គិតត្រឹមខែតុលា ឆ្នាំ២០១៩ សំណើគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៩ មានចំនួន **៤៦១គម្រោង** ដែលក្នុងនោះ៖ គម្រោងកំពុងដំណើរការសិក្សាចំនួន **១៣៨គម្រោង** (ស្មើនឹង២៩,៩៣%) គម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **២៨១គម្រោង** (ស្មើនឹង៦០,៩៥%) និងគម្រោងមិនទាន់សិក្សាចំនួន **៤២គម្រោង** (ស្មើនឹង០៩,១១%)។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៩ មានចំនួន **៦៧កិច្ចសន្យា** ក្នុងនោះ រួមមាន៖ បញ្ចប់កិច្ចសន្យាសាងសង់១០០% ចំនួន **២២**(ស្មើនឹង ៣៦,៨៤%)កិច្ចសន្យាអនុវត្តបានលើស៥០% ចំនួន**១២គម្រោង** (ស្មើនឹង១៧,៩១%) កិច្ចសន្យាអនុវត្តបានតិចជាង៥០%ចំនួន ១០(ស្មើនឹង១៤,៩៣%) និងកិច្ចសន្យាមិនទាន់បានអនុវត្តចំនួន២៣(ស្មើនឹង៣៤,៣៣%)។ ជាមួយគ្នានេះដែរ សំណើគម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៨មានចំនួន **៤៨៨គម្រោង** ដែលក្នុងនោះ៖ គម្រោងមិនទាន់សិក្សា ចំនួន២៤គម្រោង (ស្មើនឹង៤,៩២%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **៤៦៤គម្រោង** (ស្មើនឹង ៩៥,០៨%)។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៨ មានចំនួន **៣៧៣កិច្ចសន្យា** ក្នុងនោះរួមមាន៖ បានបញ្ចប់ការសាងសង់ ១០០% ចំនួន ៣៥៩ (ស្មើនឹង ៩៦,២៥%) ការអនុវត្តកិច្ចសន្យាបានលើសពី៥០%ចំនួន ១១(ស្មើនឹង២,៩៥%) ការអនុវត្តកិច្ចសន្យាបានតិចជាង៥០%ចំនួន ២(ស្មើនឹង០,៥៤%) និងកិច្ចសន្យាមិនទាន់បានអនុវត្តចំនួន ០១(ស្មើនឹង០,២៧%)។

### ៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់

សំណើគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៩មានចំនួន **១.៧៩៨គម្រោង**(ក្នុងនោះគម្រោងដែលកំពុងសិក្សាចំនួន **៣២៤គម្រោង** "ស្មើនឹង១៨,០២%" គម្រោងដែលមិនទាន់ចាប់ផ្តើមសិក្សាចំនួន ៤៣គម្រោង" ស្មើនឹង ២,៣៩% " និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន ១.៤៣១គម្រោង(ស្មើនឹង ៧៩,៥៩%)។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៩សរុបចំនួន ១.០០១កិច្ចសន្យា ក្នុងនោះរួមមាន៖ ការអនុវត្តកិច្ចសន្យាបានលើសពី៥០%ចំនួន១៨៥(ស្មើនឹង១៨,៤៨%)ការអនុវត្តកិច្ចសន្យាបានតិចជាង៥០% ចំនួន **១៧០** (ស្មើនឹង១៦,៩៨%) បញ្ចប់កិច្ចសន្យាសាងសង់១០០%ចំនួន **២០៨**(ស្មើនឹង២០,៧៨%) និងកិច្ចសន្យាមិនទាន់បានអនុវត្តចំនួន ៤៣៨(ស្មើនឹង៤៣,៧៦%)។

ដោយឡែកការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៨មានចំនួន ១.៧៦៤គម្រោង(ក្នុងនោះគម្រោងដែលកំពុងសិក្សាចំនួន ០៦គម្រោង "ស្មើនឹង០,៣៤%" និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន ១.៧៥៨គម្រោង

ស្មើនឹង៩៩,៦៦%") ។ ទន្ទឹមនោះ ការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៨សរុបចំនួន ១.៧៣៥កិច្ចសន្យា ក្នុងនោះរួមមាន៖ ការអនុវត្តកិច្ចសន្យាបានលើសពី៥០%ចំនួន ៩៦(ស្មើនឹង៥,៥៣%) ការអនុវត្តកិច្ចសន្យាបានតិចជាង៥០%ចំនួន ២៩(ស្មើនឹង ១,៦៧%) ការបញ្ចប់កិច្ចសន្យាសាងសង់១០០%ចំនួន ១.៥៩៦(ស្មើនឹង៩១,៩៩%) និងកិច្ចសន្យាមិនទាន់បានអនុវត្តចំនួន ១៤(ស្មើនឹង០,៨១%)។

**៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន**

**៧.៦.១-ការផ្ទេរមុខងារ និងធនធាន**

ក្នុងខែតុលា ឆ្នាំ២០១៩នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានសម្របសម្រួលសហការជាមួយក្រសួងនានាដូចខាងក្រោម៖

-បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយក្រសួងពាក់ព័ន្ធនានា ដើម្បីកំណត់ទំហំធនធានជាក់លាក់នៃមុខងាររបស់ក្រសួងពាក់ព័ន្ធនានាដែលបានកំណត់ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក

-បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាល រាជធានី ខេត្ត

-បានចូលរួមកិច្ចប្រជុំពិភាក្សាលើបញ្ជីមុខងារក្នុងវិស័យអប់រំដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-បានចុះទៅសិក្សា អំពីស្ថានភាពនៃការអនុវត្តមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងការប្រើប្រាស់កញ្ចប់សេវាអនាម័យបរិស្ថានជាមួយនឹងរដ្ឋបាលខេត្ត រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកមួយចំនួន នៅខេត្តស្វាយរៀង និងខេត្តព្រៃវែង។

**៧.៦.២-ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ**

**ក.ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ**

ក្នុងខែតុលា ឆ្នាំ២០១៩នេះ អង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្តបានផ្តល់សេវារដ្ឋបាលសរុបចំនួន ៥០.៤៤៤សេវា ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថាវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានផ្តល់សេវាបានច្រើនជាងគេគឺ ចំនួន ២១.២៨២សេវា(ស្មើនឹង ៤២,១៩%)វិស័យដែលបានផ្តល់សេវាបានតិចជាងគេគឺវិស័យវប្បធម៌ និងវិចិត្រសិល្បៈមានចំនួន ០១សេវា (ស្មើនឹង០,០០២%)(**ដូចក្នុងឧបសម្ព័ន្ធ**៤) ។ ជាមួយគ្នានេះដែរ អង្គភាពច្រកចេញចូលតែមួយទាំង ២៥រាជធានី ខេត្តទទួលបានចំណូលសរុបចំនួន ៥.៤១៥.២៥៧.៨៩៤រៀល (ស្មើនឹង ១.៣៥៣,៨១៤,៤៧៣ដុល្លារអាមេរិក) ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបានក្នុងចំណោមវិស័យទាំង១៤ឃើញថា វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន ៤.១៨៩.៤២៧.០៤៨រៀល (ស្មើនឹង ៧៧,៣៦% នៃសេវាសរុប) បន្ទាប់មកវិស័យដែលមានចំណូលតិចជាងគេនោះគឺ វិស័យវប្បធម៌ និងវិចិត្រសិល្បៈចំនួន ២០០.០០សេវា (ស្មើនឹង ០,០០៤%)(**ដូចក្នុងឧបសម្ព័ន្ធ៥**)។

ទន្ទឹមនោះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានសម្របសម្រួលជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យ និងកែសម្រួលលើទម្រង់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាសម្រាប់ការផ្តល់សេវារដ្ឋបាល នៅអង្គភាពច្រកចេញចូលតែមួយ ព្រមទាំងបានទំនាក់ទំនងទៅរដ្ឋបាលរាជធានី ខេត្តទាំងអស់អំពីការបែងចែកចំណូលដែលប្រមូលបានទៅឱ្យមន្ទីជំនាញ និងក្រសួងពាក់ព័ន្ធ។

**ខ.ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ**

គិតត្រឹមខែតុលា ឆ្នាំ២០១៩ ការិយាល័យច្រកចេញចូលតែមួយទាំង៨៣គោលដៅ បានផ្តល់សេវារដ្ឋបាលសរុបចំនួន១៣៥.៦៥២សេវា ក្នុងនោះបើប្រៀបធៀបចំនួនសេវា ដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង ១៤ ឃើញថាវិស័យនីត្យានុកូលកម្មបានផ្តល់សេវាបានច្រើនជាងគេគឺចំនួន ៣៤.៤៨៩សេវា(ស្មើនឹង២៥,៤២%) បន្ទាប់មកវិស័យរ៉ែ និងថាមពលទទួលបានសេវាតិចជាងគេចំនួន ០១សេវា(ស្មើនឹង០,០០១%)(**ដូចក្នុងឧបសម្ព័ន៦**)។

យេះពេលដូចគ្នានេះដែរ ការិយាល័យច្រកចេញចូលតែមួយទាំង៨៣គោលដៅទទួលបានចំណូលសរុបចំនួន ១.៩២៧.៣៤៥.៦១០រៀល (ស្មើនឹង ៤៨១.៨៣៦.៤០២ ដុល្លារអាមេរិក) ក្នុងនោះ បើប្រៀបធៀបចំណូលដែលទទួលបានពីវិស័យទាំង ១៤ ឃើញថា វិស័យសុរិយាដីមានចំណូលខ្ពស់ជាងគេគឺចំនួន ១.២១៦.៨១០.០០០រៀល(ស្មើនឹង ៦៣,១៣%) និងវិស័យដែលបានចំណូលតិចជាងគេគឺ វិស័យរ៉ែ និងថាមពលចំនួន ៥០.០០០រៀល (ស្មើនឹង០,០០៣%) (ដូចក្នុងឧបសម្ព័ន្ធ៧)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តសកម្មភាពមួយចំនួនដើម្បីគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយដូចខាងក្រោម៖

-គាំទ្រផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងការផ្តល់សេវាតាម វិស័យជំនាញដល់ក្រុង ស្រុក ខណ្ឌមួយចំនួន

-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីតួនាទី ភារកិច្ច និងរបៀបរបបបំពេញការងាររបស់ការិយាល័យច្រកចេញចូលតែមួយស្រុកគោលដៅថ្មីឆ្នាំ២០១៩

-បានគាំទ្រការិយាល័យច្រកចេញចូលតែមួយខណ្ឌដង្កោ ខណ្ឌសែនសុខ ខណ្ឌចំការមន ខណ្ឌដូនពេញ ក្រុងប៉ោយប៉ែត កែប្រព័ន្ធ MIS អោយអនុគ្រោះការបញ្ជាក់វិញ្ញាបនបត្រមធ្យមសិក្សាទុតិយភូមិ មធ្យមសិក្សាបឋមភូមិ ឆ្នាំ២០១៩

-បានទំនាក់ទំនងទៅស្រុកគោលដៅថ្មីឆ្នាំ២០១៩ អំពីការជ្រើសរើសមន្ត្រីសម្រាប់បំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ

-បានជូនដំណឹងទៅសាលារាជធានីឱ្យរៀបចំដាក់ឱ្យដំណើរការជាបណ្តោះអាសន្នការិយាល័យច្រកចេញ-ចូលតែមួយខណ្ឌកំបូល និងខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ។

### ៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**ក).ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ក្នុងខែតុលា ឆ្នាំ២០១៩នេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តបានទទួលបណ្តឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធនិងមិនពាក់ព័ន្ធសរុបចំនួន ៣៩ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន០៧ករណី បណ្តឹងក្រៅសមត្ថកិច្ចចំនួន១៣ករណី សំណូមពរចំនួន ០៤ករណី និងការសាកសួរព័ត៌មានផ្សេងៗចំនួន១៥ករណី ។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តកិច្ចការមួយចំនួន ដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដូចខាងក្រោម៖

-បានធ្វើបទបង្ហាញស្តីពីសមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ ការបំពេញការងារនៅតុពិសេសឱ្យកាន់តែមានប្រសិទ្ធភាព ការរៀបចំផែនការសកម្មភាពប្រចាំខែ របស់ការិយាល័យប្រជាពលរដ្ឋដល់ប្រធាន និងបុគ្គលិកការិយាល័យប្រជាពលរដ្ឋ ខេត្តកណ្តាល។

-រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យអំពីការរៀបចំ និងការដាក់ឱ្យដំណើរការយន្តការច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅខេត្តសៀមរាប

-រៀបចំឯកសារពាក់ព័ន្ធនានាស្តីពីការចុះគាំទ្រ និងតាមដាន លើការអនុវត្តការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានីភ្នំពេញ និងខេត្តកណ្តាល

-បានតាមដាន និងគាំទ្រលើការដាក់ឲ្យដំណើរការរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តពាក់ព័ន្ធនឹងការតែងតាំងបុគ្គលិកសម្រាប់បំពេញការងារ ការបំពាក់សម្ភារប្រើប្រាស់ ការអនុវត្តតួនាទី ភារកិច្ច និងបញ្ហាប្រឈមនានារបស់ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ។

**ខ).ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

ក្នុងខែតុលាឆ្នាំ២០១៩នេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌបានទទួលបណ្តឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធនិងមិនពាក់ព័ន្ធសរុបចំនួន ៦១៥ករណី ដែលបណ្តឹងក្នុងសមត្ថកិច្ច ១៨ករណី (ក្នុងនោះបញ្ចប់ការដោះស្រាយ ១៦ករណី កំពុងដោះស្រាយ០២ករណី) និងបណ្តឹងក្រៅសមត្ថកិច្ចចំនួន ០៧ករណី ការសរសើរចំនួន ២៦ករណី សំណូមពរចំនួន ៣៧ករណី ការសាកសួរព័ត៌មានផ្សេងៗចំនួន ៥៥២ករណី) ។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួនដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋដូចខាងក្រោម៖

-បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យ ក្រុង ស្រុក ខណ្ឌគោលដៅថ្មីចំនួន៣២ នៃឆ្នាំ២០១៩នៅសាលប្រជុំអាគារ"ទ" ទីស្តីការក្រសួងមហាផ្ទៃ

-បានគាំទ្រការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអំពីប្រព័ន្ធកត់ត្រាបណ្តឹង និងការរៀបចំរបាយការណ៍។

**៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ក្នុងខែតុលាឆ្នាំ២០១៩នេះ ក្រសួងមហាផ្ទៃបានធ្វើលិខិតជម្រាបជូនទៅក្រសួងស្ថាប័ន និងអង្គភាពនានាដូចខាងក្រោម៖

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ករណីស្តីពីការរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧។

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការធិការចំរុះកិច្ចការព្រំដែន ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម និងរដ្ឋបាលខេត្តកណ្តាល ដើម្បីស្នើសុំអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊្វរ និងព្រែកជ្រៃធំ-ព្រែកប៊ិញយី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងមហាផ្ទៃ។

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណីសំណើសុំចាត់តាំងសមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ដើម្បីចូលរួមក្រុមការងាររៀបចំ និងលើកទឹកចិត្តគម្រោងចំណតសាធារណៈ។

-ក្រសួងពាណិជ្ជកម្ម ករណីសំណើសុំពិនិត្យនិងផ្តល់ធាតុចូលលើសេចក្តីព្រាងកិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម។

-អគ្គាធិការដ្ឋាន ករណីសំណើសុំមន្ត្រីជំនាញ ដើម្បីចូលរួមក្នុងក្រុមការងារចុះធ្វើអធិការកិច្ចលើដីកាលេខ ០៦៦ដក.ឧបជ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១០ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ។

-សាលារាជធានីភ្នំពេញ ករណីរៀបចំកម្មវិធីទិវាគ្រូបង្រៀនពិភពលោកឆ្នាំ២០១៩កាលពីថ្ងៃទី០៥ខែតុលាឆ្នាំ ២០១៩ នៅទីលានប្រជាធិបតេយ្យ។

**៩.ការងារតាមវិស័យផ្សេងៗ**

**៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន**

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា មានច្រកទ្វារព្រំដែនសរុបចំនួន ៨២ច្រក រួមមាន ច្រកទ្វារកំពង់ផែអន្តរជាតិ ចំនួន ០៣ច្រក ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារព្រំដែនអន្តរជាតិចំនួន ២៦ច្រក ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ១៤ច្រក ច្រកទ្វារតំបន់ព្រំដែនចំនួន ២៦ច្រក និងច្រកទ្វារកំពង់ផែសមុទ្រចំនួន ១០ច្រក។ ទន្ទឹមនោះ ក្រសួងមហាផ្ទៃ ក៏បានណែនាំកិច្ចការមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

-រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ករណីស្តីពីការបង់ថវិកាង្វាន់នៃចំណូលដែលប្រមូលបានពីកម្រៃសេវាផ្តល់ប័ណ្ណព្រំដែនជូនមកក្រសួងមហាផ្ទៃ។

-រដ្ឋបាលខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តកោះកុង ករណីស្តីពីការពង្រឹងបន្ថែមនូវការងារផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ។

គិតចាប់ពីថ្ងៃទី១៩ ខែកញ្ញា ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ អគ្គនាយកដ្ឋានរដ្ឋបាលបានបើកផ្តល់ប័ណ្ណព្រំដែនជូនរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ និងរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវសរុបចំនួន ១៤០០០ ក្បាល(ក្នុងនោះខេត្តបាត់ដំបង៥.០០០ក្បាល ខេត្តប៉ៃលិន ៤.០០០ក្បាល និងខេត្តបន្ទាយមានជ័យ៥.០០០ក្បាល)។ ចំពោះរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានចេញប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន ១១.៩៩០ក្បាល ជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការ ដែលរួមមាន៖ ខេត្តបាត់ដំបង ៦.០១៣ក្បាល ខេត្តបន្ទាយមានជ័យ២.០៤៥ក្បាល ខេត្តឧត្តរមានជ័យ១.០៥៤ក្បាល ប៉ៃលិន ២.១៥៨ក្បាល និងខេត្តកោះកុងចំនួន ៣១២ក្បាល។

**៩.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាជាមិត្ត ក្រសួងមហាផ្ទៃបានដាក់ចេញនូវគោលការណ៍ណែនាំដល់រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពចំណុះក្រសួង ដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណីស្នើ ៖

• សុំគោលការណ៍អនុញ្ញាតឱ្យ គណៈប្រតិភូរាជធានីភ្នំពេញទៅចូលរួមកិច្ចប្រជុំ នៅទីក្រុងយូកូហាម៉ា ប្រទេសជប៉ុន។

• សុំគោលការណ៍អនុញ្ញាតឱ្យអភិបាលរង្គាកស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញ ទៅចូលរួមសន្និសីទ នៅប្រទេសសិង្ហបុរី។

-រដ្ឋបាលខេត្តកោះកុង ករណីស្នើ ៖

• សុំគោលការណ៍អនុញ្ញាតឱ្យគណៈប្រតិភូខេត្តទៅចូលរួម "ពិធីបុណ្យវប្បធម៌ Chrysanthemum លើកទី៣៧" នៅក្រុងខាយហ្វឹង នៃសាធារណរដ្ឋប្រជាមានិតចិន។

• សុំគោលការណ៍អនុញ្ញាតឱ្យគណៈប្រតិភូសកាតំណាងប្រជាជនតំបន់ស្វយ័តជនជាតិជាំង ខេត្តក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន មកបំពេញទស្សនៈកិច្ចជាផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា។

• សុំគោលការណ៍អនុញ្ញាតឱ្យប្រតិភូខេត្តទៅចូលរួមវេទិកាបណ្តាញរដ្ឋបាលមូលដ្ឋានដើម្បីការអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយចីរភាពប្រចាំឆ្នាំ២០១៩ នៅក្រុង Xiamen ខេត្ត Fujian នៃសាធារណរដ្ឋប្រជាមានិតចិន។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណីស្នើ ៖

-សុំគោលការណ៍អនុញ្ញាតឱ្យប្រតិភូខេត្តបន្ទាយមានជ័យ ទៅចូលរួមសន្និសីទអន្តរជាតិ នៅប្រទេសម៉ុងហ្គោលី និងទៅបំពេញទស្សនកិច្ចសិក្សានៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។

- សុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលក្រុងប៉ោយប៉ែត នៃខេត្តបន្ទាយមានជ័យចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការជាមួយខណ្ឌចុងណូហ្គូ ក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ។

-រដ្ឋបាលខេត្តសៀមរាប ករណីស្នើ៖

• សុំគោលការណ៍អនុញ្ញាតឱ្យឯកឧត្តម តុង ហ៉ា អភិបាលរងខេត្តយូណាន ជួបពិភាក្សាការងារជាមួយអភិបាល នៃគណៈអភិបាល ខេត្តសៀមរាប។

• សុំគោលការណ៍អនុញ្ញាតឱ្យគណៈប្រតិភូខេត្តទៅចូលរួមពិធីបុណ្យវប្បធម៌ហ្វាសុងស៊ូវ៉ុនលើកទី៥៦ នៅទីក្រុងស៊ូវ៉ុន នៃសាធារណរដ្ឋកូរ៉េ។

• សុំគោលការណ៍អនុញ្ញាតឱ្យគណៈប្រតិភូខេត្តទៅចូលរួមកម្មវិធីAsean Japan Smart Cities Network High Level Meeting នៅទីក្រុង Yokohama ខេត្ត Kanagawa ប្រទេសជប៉ុន។

-រដ្ឋបាលខេត្តព្រះសីហនុ ករណីស្នើ៖

• សុំគោលការណ៍អនុញ្ញាតឱ្យគណៈប្រតិភូខេត្តទៅចូលរួមខួបអនុស្សាវរីយ៍លើកទី៤០ ស្តីពីការភ្ជាប់ទំនាក់ទំនងខេត្ត-ក្រុងមិត្តភាពអន្តរជាតិរបស់ទីក្រុងឈីងតាវ និងចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាជាមួយទីក្រុងឈីងតាវ នៃសាធារណរដ្ឋប្រជាមានិតចិន។

• សុំគោលការណ៍អនុញ្ញាតឱ្យប្រតិភូខេត្តចូលរួម"ពិព័រណ៍ចិន-អាស៊ានលើកទី១៦" នៅទីក្រុងណាននីង តំបន់ស្វយ័តខេត្តក្វាងស៊ីនៃសាធារណរដ្ឋប្រជាមានិតចិន។

-រដ្ឋបាលខេត្តប៉ៃលិន ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលខេត្តចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការចងសម្ព័ន្ធមេត្រីភាពជាមួយខេត្តឡុងអាន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-រដ្ឋបាលខេត្តបាត់ដំបង ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យឯកឧត្តម យឹម សៀប អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង ទៅចូលរួមកម្មវិធី "The Cities 4.0 Conference and Exhibition 2019" នៅប្រទេសម៉ាឡេស៊ី។

-រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តព្រះសីហនុ ករណីសំណើសុំជួបពិភាក្សាការងាររបស់គណៈប្រតិភូសាលាក្រុង Pyeongtaek នៃសាធារណរដ្ឋកូរ៉េ។

-រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តសៀមរាប ករណី៖

• ស្ថានទូតជប៉ុនរៀបចំការិយាល័យបោះឆ្នោត ដើម្បីជ្រើសរើសសមាជិកព្រឹទ្ធសភា នៅភ្នំពេញ និងខេត្តសៀមរាប។

• សំណើសុំគោលការណ៍អនុញ្ញាតឱ្យ គណៈប្រតិភូខេត្តបារៀ-វ៉ុងតាវ ដឹកនាំដោយឯកឧត្តម ង្វៀន ហុងលិញ (NGUYEN HONG LINH) ជាសមាជិកគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនិស្តវៀតណាម លេខាបក្សខេត្ត និងជាប្រធានក្រុមប្រឹក្សាប្រជាជនខេត្តមកបំពេញទស្សនកិច្ចនៅកម្ពុជា។

-រដ្ឋបាលខេត្តព្រះវិហារ ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យគណៈប្រតិភូខេត្តចំនួន ០៥រូប ទៅបំពេញទស្សនកិច្ចសិក្សានៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។

### ៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ

ក្នុងខែតុលា២០១៩នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចលើសំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៩ចំនួន **៧២**គម្រោងរបស់រដ្ឋបាលខេត្តចំនួន**៧** រួមមាន៖ ខេត្តបាត់ដំបង(២៦គម្រោង) ខេត្តប៉ៃលិន(២៣គម្រោង) ខេត្តកំពង់ស្ពឺ(៥គម្រោង) ខេត្តតាកែវ(៦គម្រោង) ខេត្តកំពត(៥គម្រោង) ខេត្តព្រះសីហនុ(៥គម្រោង) និង ខេត្តស្វាយរៀង(២គម្រោង)មានទឹកប្រាក់ចំនួន **៧៥.៦៧០.៥៥០.០០០**រៀល(ចិតសិបប្រាំបីលានប្រាំមួយរយចិតសិបលានប្រាំរយហាសិបពាន់រៀលគត់) (**ដូចក្នុងឧបសម្ព័ន្ធ៨**) ។ ទន្ទឹមនោះ ថ្នាក់ដឹកនាំក៏បានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍឆ្នាំ២០១៩ចំនួន **១៩គម្រោង** របស់រដ្ឋបាលខេត្តចំនួន៤ រួមមាន៖ ខេត្តកំពង់ឆ្នាំង(៥គម្រោង) ខេត្តកំពត(៩គម្រោង) ខេត្តព្រះសីហនុ(៤គម្រោង)និងខេត្តស្វាយរៀង(១គម្រោង)ដែលមានទឹកប្រាក់ចំនួន **២៣.៨៣៥.៧៧២.០០០**រៀល (ម្ភៃបីប៊ីលានប្រាំបីរយសាមសិបប្រាំលានប្រាំពីររយចិតសិបពីរពាន់រៀលគត់)(**ដូចក្នុងឧបសម្ព័ន្ធ៩**)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃជម្រាបទៅក្រសួងស្ថាប័ននានាពាក់ព័ន្ធនឹងសំណើរបស់រដ្ឋបាលខេត្តមួយចំនួនដូចខាងក្រោម៖

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖

• ករណីរដ្ឋបាលខេត្តព្រះវិហារ ស្នើសុំគោលការណ៍កាត់ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលស្រុកសង្គមថ្មី នូវដីបេនឡានទំហំ ២.០០០ម៉ែត្រការ៉េ ក្នុងនោះដីទំហំ ១.៦៧៣ម៉ែត្រការ៉េ សម្រាប់ចែកជូនប្រជាពលរដ្ឋចំនួន ០៧គ្រួសារ និងដីទំហំ ៣២៧ម៉ែត្រការ៉េ សម្រាប់ធ្វើផ្លូវសាធារណៈ

• សំណើសុំចាត់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមក្នុងក្រុមការងារដោះស្រាយដីបង្គុកស្ថិតក្នុងភូមិជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល សម្រាប់បម្រុងទុកសាងសង់អគារទីស្នាក់ការ និងហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារព្រំដែនអន្តរជាតិជ្រៃធំ។

**-ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងធនធានទឹក និងឧតុនិយម** ករណីរដ្ឋបាលខេត្តកណ្តាល ស្នើសុំជួលទីតាំងដីទំហំ ២២៣ ហិកតា ២.៧៥១ ម៉ែត្រការ៉េ ដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ពាណិជ្ជកម្ម ពហុបំណងរបស់ក្រុមហ៊ុនអាណាចក្រឌីវេឡុបមេនគ្រុប ដែលមានទីតាំងស្ថិតនៅឃុំសំពោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

### ៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

គិតមកដល់បច្ចុប្បន្នសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជី នៅក្រសួងមហាផ្ទៃសរុបចំនួន **៥.៥៣០** (ក្នុងនោះសមាគមចំនួន **២.២២២** អង្គការមិនមែនរដ្ឋាភិបាលចំនួន **៣.៣០៨**) និងសហគមន៍ជនជាតិ

ដើមភាគតិចចំនួន ១៣៧ ។ ក្នុងខែតុលា ឆ្នាំ២០១៩នេះ ក្រសួងមហាផ្ទៃបានចុះបញ្ជីសមាគម អង្គការមិនមែន-រដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិចសរុបចំនួន ២៣(ក្នុងនោះសមាគម ១១ និងអង្គការមិនមែនរដ្ឋាភិបាល ១២) និងបានលុបឈ្មោះសមាគមចំនួន ០១(ដូចក្នុងឧបសម្ព័ន្ធ១០)។ ជាមួយគ្នានេះផងដែរ ក៏បានបញ្ចូលទិន្នន័យស្កេនសំណុំឯកសារពាក់ព័ន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣០ច្បាប់ ក្នុងនោះ សមាគមចំនួន ១៨ច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១២ច្បាប់។

ទន្ទឹមនេះ ក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចពាក់ព័ន្ធនឹងការងារនានាដូចជាការសុំចុះឈ្មោះក្នុងបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន ការសុំផ្លាស់ប្តូរសមាសភាពថ្មី នៃចេនាសម្ព័ន្ធ ការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ ការផ្អាកសកម្មភាពបណ្តោះអាសន្នចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ លើសពីនេះ ក៏បានបញ្ជូនប្រកាស និងសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃទៅឱ្យសាមីសាមាគម អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធសរុបចំនួន ២៣ច្បាប់ ក្នុងនោះសមាគមចំនួន ១១ច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១២ច្បាប់ (ដូចក្នុងឧបសម្ព័ន្ធ ១១)។

### ៩.៤.២-ការងារគណបក្សនយោបាយ

គិតមកដល់បច្ចុប្បន្នគណបក្សនយោបាយមានចំនួនសរុប ៤៤គណបក្ស ក្នុងនោះគណបក្សដែលបានចុះបញ្ជីចំនួន ៤៣គណបក្ស និងគណបក្សដែលបានបង្កើតចំនួន ០១គណបក្ស។

## II-បញ្ហាប្រឈម និងសំណូមពរ

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញភារកិច្ចកន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-ការបញ្ជូនឯកសារពីក្រសួងមហាផ្ទៃទៅកាន់រដ្ឋបាលរាជធានី ខេត្ត និងការបញ្ជូនឯកសារពីរដ្ឋបាលរាជធានី ខេត្តមកក្រសួងមហាផ្ទៃនៅតែមានភាពយឺតយ៉ាវ។

-ការផ្គត់ផ្គង់សម្ភារៈការិយាល័យដូចជាក្រដាស ទឹកថ្នាំ ម៉ាស៊ីនថតចម្លងដើម្បីប្រើប្រាស់បំពេញការងារមិនគ្រប់គ្រាន់

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្តមានភាពយឺតយ៉ាវ បន្ទាប់ពីបញ្ចប់បេសកកម្ម មន្ត្រីរាជការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុន។

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារ អគ្គនាយកដ្ឋានរដ្ឋបាល សំណូមពរដូចខាងក្រោម៖

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានសមស្រប និងទាន់ពេលវេលាសម្រាប់បំពេញការងារ

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនជាងមុនបន្ទាប់ពីចុះបេសកកម្ម។

## III-ទិសដៅការងារបន្ត

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការដែលបានគ្រោងទុក អគ្គនាយកដ្ឋានរដ្ឋបាលបានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៩ ដូចខាងក្រោម៖

### ១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

#### ១.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងដែលកំពុងរៀបចំ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត និងការលុបចោលភូមិ និងការកែសម្រួលព្រំប្រទល់រដ្ឋបាល នៃរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

-សេចក្តីព្រាងប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត និងលុបបោលភូមិ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សា នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី«កិច្ចការរដ្ឋបាល»សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ

-សេចក្តីព្រាងក្របខ័ណ្ឌ តាមដាន ត្រួតពិនិត្យ វាយតម្លៃ លើផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាព មន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**១.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័នរដ្ឋបាលក្រុង

-សេចក្តីព្រាងអនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័នរដ្ឋបាលស្រុក

-សេចក្តីព្រាងអនុក្រឹត្យស្តីពី មុខងារ និងរចនាសម្ព័នរដ្ឋបាលស្រុខណ្ឌ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការបែងចែកចំណូល ដែលបានមកពីការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោមពីរឆ្នាំ ក្នុងគ្រួសារក្រីក្រ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៩ ស្តីពីការរៀបចំប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រ ខេត្តបាត់ដំបង

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបែងចែកចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រ ខេត្តបាត់ដំបង

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០២៨។

**២-ការងារបុគ្គលិក**

**២.១-ការងារក្របខ័ណ្ឌ**

-បន្តរៀបចំបែបបទសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ និងឡើងថ្នាក់ ឋានន្តរស័ក្តិតាមកម្រិតសញ្ញាបត្រ ជូនមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០២០

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មីនិងអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីសុំពិនិត្យនីត្យានុកូលភាពលើប្រកាសតែងតាំង និងប្រគល់ភារកិច្ច ដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសាលាកប័ត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

-រៀបចំពិនិត្យផ្ទៀងផ្ទាត់សលាបត្រមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ដែលដល់អាយុត្រូវចូលនិវត្តន៍ឆ្នាំ២០២០

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាពនិងមន្ត្រីរាជការដែលសុំលាឈប់ពីការងារ

-បន្តរៀបចំការផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាត ឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញ បន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយហួសកាលកំណត់

-បន្តរៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព

-បន្តរៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ធានារ៉ាប់រងសង្គម

-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយសមេដាយការងារ និងប័ណ្ណសរសើ ជូនមន្ត្រីរាជការស៊ីវិល។

**២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

-បន្តរៀបចំផ្លាស់ប្តូរកន្លែងធ្វើការ រៀបចំដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិរយៈពេល ០៣ ខែសម្រាប់មន្ត្រីរាជការស៊ីវិល និងដាក់ទណ្ឌកម្មខាងវិន័យសម្រាប់មន្ត្រីពន្ធនាគារនិងរៀបចំតារាងបៀវត្សកែតម្រូវឱ្យត្រូវតាមរចនាសម្ព័ន្ធនៃអង្គភាពនីមួយៗ

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពទីប្រឹក្សា ជំនួយការក្រសួងមហាផ្ទៃ និងទីប្រឹក្សាជំនួយការសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

-បន្តរៀបចំធ្វើបច្ចុប្បន្នភាពសម្រាប់ខែបន្ទាប់របស់មន្ត្រីរាជការស៊ីវិលនិងមន្ត្រីពន្ធនាគារឱ្យមានភាពត្រឹមត្រូវនៅទីស្តីការក្រសួងមហាផ្ទៃ

-បន្តត្រៀមរៀបចំក្រុមការងារពិពណ៌នាមុខតំណែងមន្ត្រីរាជការ

-បន្តធ្វើការតែងតាំង ទីប្រឹក្សា និងជំនួយការក្រសួងមហាផ្ទៃ។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-ពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការចុះពង្រឹងរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីរាជការនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

-បន្តសហការ និងសម្របសម្រួលជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយ លើការងារប្រកាសទ្រព្យសម្បត្តិ និងបំណុលសម្រាប់ឆ្នាំ២០១៩

-បន្តពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំ( និង០៨ឆ្នាំ )របស់ខ្លួន

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តយកចិត្តទុកដាក់ពិនិត្យលើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-សិក្សា និងរៀបចំភ្ជាប់ប្រព័ន្ធ គ្រប់គ្រងទិន្នន័យគ្រប់ការិយាល័យដែលពាក់ព័ន្ធចំណុះនាយកដ្ឋានបុគ្គលិក

-បន្ទាប់ពីរៀបចំប្រព័ន្ធបានដំណើរការរួចរាល់ ការិយាល័យចាប់ផ្តើមធ្វើបច្ចុប្បន្នភាពគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងប្រព័ន្ធ ទិន្នន័យដោយចាប់ផ្តើមពីខេត្តបន្ទាយមានជ័យ

-សហការជាមួយការិយាល័យជំនាញពាក់ព័ន្ធក្នុងនាយកដ្ឋាន ដើម្បីធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដូចជា៖ ការផ្លាស់ប្តូរទីកន្លែងធ្វើការ ការតែងតាំង ការប្រែប្រួលថ្នាក់ ឋានន្តរស័ក្តិ ការលុបឈ្មោះ ការចូលនិវត្តន៍...។ល។

**៣-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

-ត្រៀមរៀបចំបណ្តុះបណ្តាលវគ្គវិក្រឹត្យការមូលដ្ឋានសម្រាប់ក្រុមគោលដៅជាមន្ត្រីបម្រើការងារនៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ

-បន្តរៀបចំឯកសារមេរៀនវគ្គលេខាធិការរដ្ឋបាល

-បន្តរៀបចំឯកសារបណ្តុះបណ្តាលសម្រាប់ស្មៀនឃុំ-សង្កាត់

-បន្តរៀបចំ និងចងក្រងវិធីសាស្ត្របណ្តុះបណ្តាល ដើម្បីបង្កើតជាឯកសារ

-បន្តចងក្រងទិន្នន័យអភិវឌ្ឍសមត្ថភាព

-បន្តរៀបចំផែនការបណ្តុះបណ្តាលមន្ត្រីរាជការ នៅរដ្ឋបាលក្រុង ស្រុក ក្រោយសមាហរណកម្មការិយាល័យជំនាញចូលក្នុងរចនាសម្ព័ន្ធរដ្ឋបាល ក្រុង ស្រុក

-បាន និងកំពុងរៀបចំវឌ្ឍនភាពសកម្មភាពឆ្នាំ២០១៩ របស់ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ(SPCD)។

**៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

-បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស

-បន្តសហការជាមួយដៃគូ ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការតាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន**

- បន្តធ្វើបច្ចុប្បន្នភាពនិងបញ្ចូលអត្ថបទក្នុងគេហទំព័រអេត្តនាយកដ្ឋានរដ្ឋបាល

- បន្តស្រាវជ្រាវ និងសរសេរអត្ថបទ ដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ «វិមជ្ឈការ និងវិសហមជ្ឈការ» ក្រសួងមហាផ្ទៃលេខ ០៤។

## ៥-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

### ៥.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍

ដើម្បីគាំទ្រដល់ការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលកំពុងបន្តពិនិត្យ លើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងលើកិច្ចការមួយចំនួនដូចខាងក្រោមៈ

-**រដ្ឋបាលខេត្តកំពត** ករណីក្រុមហ៊ុន **មីលីនដា ជូលី អ៊ីនវេសមិន ខូអិលធីឌី** ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តកំពត ដើម្បីឱ្យសាមីក្រុមហ៊ុនអាចធ្វើអាជីវកម្មយកអាចម៍ដី **៩,៧០៣១ហិកតា** ស្ថិតនៅភូមិវត្តអង្គ ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត

-**រដ្ឋបាលខេត្តព្រៃវែង** ករណីប្រជាពលរដ្ឋ ៤២៩នាក់ នៅឃុំឫស្សីស្រុក ស្រុកពាមជរ ខេត្តព្រៃវែង សុំប្តឹងឈ្មោះ **នួន ម៉េង** តួនាទីជាមេឃុំឫស្សីស្រុក និងបក្សពួកបានឃុបឃិតគ្នាបានយកប្រឡាយឧកញ៉ា ប៉ែន នួន ទៅធ្វើអាជីវកម្មបូមទឹកដាក់ស្រែប្រាំងដោយយកតម្លៃពី ៣១ម៉ឺន ទៅ ៣៧ម៉ឺនរៀល ក្នុង១ហិកតា

-**រដ្ឋបាលខេត្តបន្ទាយមានជ័យ** ករណីៈ

• ឈ្មោះ **វាល់ សុខុន, ជា ចំរើន, ព្រំ សុផាត់ និងមាស សុខា** តំណាងប្រជាពលរដ្ឋ ៣០២គ្រួសារ ស្នើសុំជួយអន្តរាគមន៍លុបសេចក្តីជូនដំណឹងលេខ ៤៨៦/១៩ សជណ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

• ឈ្មោះ **សួន ឆេត** ស្នើសុំចាត់វិធានការ និងជួយអន្តរាគមន៍លើករណីការផ្តល់ដីសម្បទានសង្គមកិច្ចទំហំ ១១ហិកតា ស្ថិតនៅចំណុចចន្ទគិរីដំណាក់ទឹក សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ សម្រាប់ចែកឱ្យប្រជាពលរដ្ឋក្រីក្រ ២៨៦គ្រួសារ

• ឈ្មោះ **សាមិ រ៉េយ៉ា** ប្តឹងលោក **គាត ហ៊ុល** អភិបាលក្រុងប៉ោយប៉ែតថាបានរំលោភបំពានលើដីទំហំ ១១៩ ហិកតា ស្ថិតនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

• ឈ្មោះ **ប៉ុន រិន, ចាន់ ផល, ញៀន ធីវ៉ា, យឿន ឡេង, វ័ន្ត សុភក្រ្ត, គត់ សារ៉ូន, សេង គឹមហៀក, សុំ វ័ត្ន,វ័ន្ត សុភ័ណ, មាស កុសល, យៀន សរ៉ាយ និងរិ សារ៉ាន់** ស្នើសុំអន្តរាគមន៍លុបចោលសេចក្តីជូនដំណឹងលេខ ៥៦៥/១៩ សជណ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

- **រដ្ឋបាលខេត្តប៉ៃលិន** ករណីឈ្មោះ **ជុំ កិល និង ផល ឌីន** ស្នើសុំអន្តរាគមន៍រកយុត្តិធម៌លើវិវាទដីធ្លីទំហំ **២៧ម៉ែត្រ x ៩០ម៉ែត្រ** និងដីកន្ទួយចំការទំហំ **២៧ម៉ែត្រ x ១៥៥ម៉ែត្រ** ព្រមទាំងដីទំហំ **៨២ម៉ែត្រ x ២១១ម៉ែត្រ** ដែលស្ថិតនៅភូមិអូរបេង ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន

- **រដ្ឋបាលខេត្តស្វាយរៀង** ករណីរបាយការណ៍បំភ្លឺបណ្តឹងប្រជាពលរដ្ឋចំនួន ៣៣គ្រួសារ ដែលបានដាក់ពាក្យប្តឹងមកក្រសួងមហាផ្ទៃ ជួយដោះស្រាយបញ្ហាវិវាទដីធ្លីចំនួន **១៥៨,៧៣ហិកតា** ដែលជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន អាន ម៉ាឌីគ្រុប ស្ថិតនៅភូមិបឹង ឃុំត្រស់ ស្រុករមាសហែក ខេត្តស្វាយរៀង

- **រដ្ឋបាលខេត្តបន្ទាយមានជ័យ** ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០២ ស្ថិតក្នុងឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

- **រដ្ឋបាលខេត្តតាកែវ** ករណីរដ្ឋបាលឃុំកំពង់រាប ស្នើសុំបំបែកភូមិ ចំនួន ០២ ស្ថិតក្នុងឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

- **រដ្ឋបាលខេត្តមណ្ឌលគិរី** ករណីធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលដោះស្រាយផលប៉ះពាល់ដីមជ្ឈមណ្ឌលវប្បធម៌ជនជាតិដើមភាគតិចភ្នំដោះក្រមុំ

- បន្តរៀបចំបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែរបស់រដ្ឋបាលរាជធានី ខេត្ត

- បន្តចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលរាជធានីភ្នំពេញ និងត្រៀមចំរបាយការណ៍បូកសរុបលទ្ធផលការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្នុងការិយបរិច្ឆេទ២០១៨

-បន្តរៀបចំ កែសម្រួលនូវប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត។

**៤.២-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

-បន្តតាមដាន ត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ១៩៧៣ស.ជ.ណ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង ការស្នើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ និងគោរមងារជាឧកញ៉ាជូនសប្បុរសជន ដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង ករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្ត បាត់ដំបង កំពង់ឆ្នាំង តាកែវ និងខេត្តស្វាយរៀង។

**៤.៣-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៤.៣.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF**

-ចុះតាមដានការអនុវត្តសកម្មភាពសេវាសង្គមនៅរាជធានី ខេត្តកោលដៅ

-រៀបចំលិខិតជូនដំណឹងស្តីពីការចុះអនុវត្តសកម្មភាពរបស់អង្គការស្តារកម្ពុជា និងអេភីអាយ លើគម្រោងលើក កម្ពស់កាចូលរួមរបស់យុវជនក្នុងការកសាងផែនការ និងថវិកាឃុំ សង្កាត់

-សហការក្នុងការរៀបចំបញ្ជីសំនួរបញ្ជីសំនួរ និងចុះសម្ភាសអ្នកពាក់ព័ន្ធផ្ទាល់ អំពីការចូលរួមរបស់យុវជនក្នុង ការរៀបចំផែនការ និងថវិកាឃុំ សង្កាត់។

**៤.៣.២-គម្រោងសាងសង់អគាររដ្ឋបាល អាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

-បន្តតាមដាន និងសម្របសម្រួលទាក់ទងនឹង សំណើសុំថវិកាបន្ថែមទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី ក្សោ ការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់តាមចំនួនដែលបានគ្រោងទុក

-បន្តចុះពិនិត្យ និងតាមដានដំណើការសាងសង់អគារសាលាស្រុក និងឃុំ សង្កាត់ដំណាក់កាលទី១ និងទី២។

**៤.៤-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

-បន្តរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យទីតាំង និងស្ថានភាពអគាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់

-បន្តទំនាក់ទំនងជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីជំរុញដំណើរការរៀបចំ និងអនុវត្តគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-បន្តតាមដាន ត្រួតពិនិត្យការរៀបចំ និងការអនុវត្តថវិកាក្រុង ស្រុក ឃុំ សង្កាត់

-បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០២០-២០២២

-បន្តប្រមូល និងរក្សាទុកទិន្នន័យនៃការអនុវត្តគម្រោង ក្រុង ស្រុក ឃុំ សង្កាត់

-បន្តប្រមូល និងរក្សាទុកបញ្ជីឈ្មោះអ្នកទទួលការប្រចាំឆ្នាំ និងបញ្ជីខ្មៅអ្នកទទួលការ

-បន្តត្រៀមរៀបចំកិច្ចប្រជុំស្តីពីស្ថានភាពនៃការគាំទ្ររបស់រដ្ឋបាលរាជធានី ខេត្តដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ លើកទី៣ ។

-បន្តសិក្សាអំពីប្រព័ន្ធសម្រាប់ថែទាំ ជួសជុល និងសាងសង់អគាររដ្ឋបាលសាលាក្រុង ស្រុក ឃុំ សង្កាត់

-បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ ២០១៩-២០២១។

**៤.៥-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

- រៀបចំពិធីសម្ពោធ និងដាក់ឱ្យដំណើរការជាផ្លូវការនូវអង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្ត

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសនៃការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញនីមួយៗដែលធ្វើ ប្រតិភូកម្មដល់ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌគោលដៅថ្មី

- សហការជាមួយក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការចុះ សិក្សាអំពីស្ថានភាពនៃការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ត្រៀមរៀបចំក្រុមការងារចុះសិក្សាអំពីទម្រង់បែបបទ និងនីតិវិធីនៃការផ្តល់សេវាក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្នុងវិស័យសាធារណការ និងដឹកជញ្ជូន។

- ត្រៀមរៀបចំកិច្ចប្រជុំដើម្បីពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តការងាររបស់អង្គភាពច្រក ចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

- តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- បន្តតាមដានលើការជ្រើសរើសមន្ត្រីរបស់ស្រុកគោលដៅថ្មីឆ្នាំ២០១៩ សម្រាប់បំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ

- ត្រៀមដាក់ចេញសេចក្តីណែនាំស្តីពីរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

- បោះពុម្ពសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ

- ចុះគាំទ្រការអនុវត្តតួនាទី ភារកិច្ចការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ចុះតាមដាន ត្រួតពិនិត្យ គាំទ្រ និងស្រាវជ្រាវបណ្តឹងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ដើម្បីលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ននានា អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់លើករណីដូចខាងក្រោម ៖

-**ក្រសួងយុត្តិធម៌** ករណី ស្នើសុំបញ្ជាក់លើផែនទីកំណត់ដែនដីរដ្ឋបាលវាងភូមិគោកត្នោត ឃុំកណ្ដែក ស្រុកប្រាសាទបាគង និងភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប

-**អគ្គាធិការដ្ឋាន** ករណីស្នើសុំចាត់មន្ត្រីជំនាញចូលរួមក្នុងក្រុមការងារចុះធ្វើអធិការកិច្ចលើដីកាលេខ ០៦៦ ដក.ខបជ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ។

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន**

-បន្តធ្វើការបូកសរុប និងសិក្សាលើកយោបល់ពាក់ព័ន្ធនឹងសកម្មភាពទូទៅរបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនក្នុងបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង

-បន្តពិនិត្យ និងលើកយោបល់ ចំពោះករណីសកម្មភាពបូមខ្សាច់របស់ភាគីវៀតណាម នៅក្បែរតំបន់ព្រំដែនកម្ពុជា-វៀតណាម ស្ថិតនៅភូមិក្អមសំណាក្រោម ឃុំក្អមសំណ ស្រុកលើកដែក ខេត្តកណ្តាល

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊ូវ និងព្រែកជ្រៃធំ-ព្រែកប៊ិញយី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម

-បន្តតាមដាន និងគាំទ្រដល់រដ្ឋបាលខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ ដល់ដំណើរការប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវប្រើប្រាស់ ព្រមទាំងបន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែននៅក្រុង ស្រុក និងច្រកទ្វារព្រំដែន នៃបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ

-បន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែនកម្ពុជា/ថៃ និងកម្ពុជា/ឡាវឱ្យមានភាពប្រសើរឡើង។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាពនិងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-ត្រៀមរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧

-បន្តពិនិត្យលើកយោបល់ ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលរាជធានីភ្នំពេញចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយរដ្ឋធានីសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ

-បន្តពិនិត្យ លើកយោបល់ ចំពោះសំណើរបស់រដ្ឋបាលខេត្តបាត់ដំបង និងក្រុងបាត់ដំបង បានសហការជាមួយគណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក (UN-ESCAP) ដើម្បីអនុវត្តគម្រោង " ការធ្វើមូលដ្ឋានីយកម្មរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការគ្រប់គ្រងធនធានទីក្រុងប្រកបដោយចីរភាព នៅខេត្តបាត់ដំបង"

-បន្តពិនិត្យ លើកយោបល់ចំពោះសំណើរបស់រដ្ឋបាលខេត្តបាត់ដំបងចងសម្ព័ន្ធមេត្រីភាព និងចុះអនុស្សរណៈ នៃការយោគយល់គ្នាជាមួយខេត្តអិហ៊ិមិ នៃប្រទេសជប៉ុន។

### ៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ

អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ចំពោះសំណើរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

**-រដ្ឋបាលខេត្តមណ្ឌលគិរី** ករណីស្នើសុំគោលការណ៍រៀបចំតំបន់រដ្ឋបាលស្រុកអូររាំងថ្មី ដោយកាត់ដីទំហំ ២១៧,៨៣២ ហិកតាស្ថិតនៅក្នុងភូមិពូរ៉ាំង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។

**-រដ្ឋបាលខេត្តបន្ទាយមានជ័យ** ករណីស្នើសុំគោលការណ៍អនុញ្ញាតធ្វើការដោះដូរទីតាំងដី និងអគាររបស់មណ្ឌលសុខភាពប៉ោយប៉ែត១ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**-រដ្ឋបាលខេត្តកំពង់ស្ពឺ** ករណីស្នើសុំដោះដូរទីតាំងមហោស្រពខេត្តកំពង់ស្ពឺ និងអភិវឌ្ឍន៍ផ្សារទំនើបក្បែរស្ពានបារាំងស្ថិតនៅសង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

**-រដ្ឋបាលខេត្តបាត់ដំបង** ករណី៖

• ស្នើសុំកាត់ដីទំហំ ៦០.៤២៥,៥២ម៉ែត្រការ៉េ ពីផ្សារបឹងឈូក ដែលស្ថិតក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តបាត់ដំបង ស្ថិតនៅភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

• ស្នើសុំកាត់ដីទំហំ ៧.៧៨១ម៉ែត្រការ៉េ ពីផ្សារ១៣មករា ដែលស្ថិតក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តបាត់ដំបង ស្ថិតនៅភូមិ១៣មករា សង្កាត់ព្រែកព្រះស្ដេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

**-រដ្ឋបាលខេត្តព្រះសីហនុ** ករណីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់គោលការណ៍លើករណីសំណើសុំជួលទីតាំងចំណតរថយន្តផ្សារលើទំហំ ៣.៣៤៦ម៉ែត្រការ៉េ ស្ថិតនៅភូមិ១ សង្កាត់លេខ ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ សម្រាប់រយៈពេល ៣០ឆ្នាំ ដើម្បីរៀបចំកែលម្អចំណតរថយន្ត និងអភិវឌ្ឍន៍សាងសង់ជាអគារពាណិជ្ជកម្មពហុបំណង។

**-រដ្ឋបាលខេត្តកំពង់ឆ្នាំង** ករណីស្នើ៖

• សុំគោលការណ៍អនុញ្ញាតពីសម្តេចក្រឡាហោម មេត្តាជួយអន្តរាគមន៍ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការពិនិត្យលទ្ធភាពផ្តល់កញ្ចប់ថវិកាសម្រាប់អនុវត្តគម្រោងសាងសង់ផ្លូវក្រាលកៅស៊ូ ១ខ្សែ (លើកំណាត់ផ្លូវលេខ ៤០) ស្របតាមច្រាំងទន្លេប្រវែង ១.៧២០ម៉ែត្រ ទទឹង ១២ម៉ែត្រ តភ្ជាប់ពីផ្លូវកៅស៊ូដែលមានបច្ចុប្បន្នទៅដល់ផែដឹកជញ្ជូន ដើម្បីដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា

• សុំគោលការណ៍អនុញ្ញាតក្នុងការផ្ទេរ និងប្រគល់កម្មសិទ្ធិស្របច្បាប់នូវដីមួយកន្លែងទំហំ ៣០៦ម៉ែត្រការ៉េ និងអគារ ០២ខ្នង សង់នៅលើដីទំហំ ២២៥ម៉ែត្រការ៉េ ស្ថិតក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់សាលាឃុំអណ្តូងស្វាយ ជូនគ្រួសារលោកស្រី មាស ណារិន ស្ថិតនៅឃុំអណ្តូងស្វាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

### ៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តលើកយោបល់អំពីការសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មីនៃរចនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ សុំលុបឈ្មោះ ការផ្អាកសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យសម្រេច

-បន្តលើកយោបល់អំពីការសុំតម្កល់សំណុំឯកសារ អំពីការផ្លាស់ប្តូរសមាសភាពរចនាសម្ព័ន្ធ និងការធ្វើវិសោធន៍កម្មលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច

-បន្តអនុវត្តការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាល ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ

-បន្តផ្តល់ការគាំទ្រកិច្ចដំណើរការរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តធ្វើបច្ចុប្បន្នភាពនិងបូកសរុបនូវរបាយការណ៍សកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គមពាក់ព័ន្ធនឹងការធ្វើសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តពិនិត្យ និងដោះស្រាយពាក្យបណ្ដឹង ឬសំណើនានារបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារវាយតម្លៃអញ្ញមញ្ញ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងចូលរួមប្រជុំជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្ដីពីការសម្អាតប្រាក់ (APG) ដើម្បីអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣

-បន្តតាមដានត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខន្តិកៈរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តចូលរួមជាមួយក្រុមការងារអន្តរក្រសួងដើម្បីដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នា នៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ICRP-JG) នៃក្រុមការងារហិរញ្ញវត្ថុ (FATF)

-បន្តរៀបចំកិច្ចប្រជុំជាមួយក្រុមការងារអន្តរក្រសួង ដើម្បីដោះស្រាយសំណើ និងសំណូមពរ របស់អង្គការសង្គមស៊ីវិល

-បូកសរុបលទ្ធផល នៃការរៀបចំវេទិកាពិគ្រោះយោបល់ស្ដីពីភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៣

-រៀបចំកិច្ចដំណើរការនៃការធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងការសិក្សាអំពីការចូលរួមវិភាគទានដើម្បីការអភិវឌ្ឍសង្គមកម្ពុជា ដោយសហការជាមួយអង្គការគណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា(CCC)

-រៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិល ក្នុងការធ្វើវិសោធនកម្មច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល រវាងក្រុមការងាររបស់រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល និងតំណាងអង្គការសង្គមស៊ីវិល។

### ៦.៤.២-ការិយាល័យគណបក្សនយោបាយ

-ជូនដំណឹងអំពីលទ្ធផលសមាជវិសាមញ្ញរបស់គណបក្សស្មើខេមរា

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយដែលបានបង្កើត បានចុះបញ្ជី និងត្រូវបានលុបឈ្មោះ

-បន្តពិនិត្យ លើកយោបល់លើសំណើសុំ បង្កើត ឬការសុំចុះបញ្ជីគណបក្សនយោបាយ និងការផ្លាស់ប្ដូរ ឬការប្រែប្រួលនានា ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច

-បន្តត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខន្តិកៈ របស់គណបក្សនយោបាយ

-បន្តតាមដានពិនិត្យបូកសរុបប្រមូលព័ត៌មានពីគ្រប់បណ្ដាព័ត៌មានសង្គម និងរបាយការណ៍របស់រដ្ឋបាលរាជធានី ខេត្ត ចំពោះគណបក្សនយោបាយ ដែលបានធ្វើសកម្មភាពផ្ទុយពីលក្ខន្តិកៈ ច្បាប់ស្ដីពី គណបក្សនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា

-ពិនិត្យ និងដោះស្រាយពាក្យបណ្ដឹង ឬសំណើនានារបស់គណបក្សនយោបាយ៕

អគ្គនាយក

ប្រាក់ សំអឿន

<u>ចម្លងជូន៖</u>

*-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
*(ជូនជ្រាបជាសេចក្ដីរាយការណ៍)*
*-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ*
*-អគ្គស្នងការដ្ឋាននគរបាលជាតិ*
*-អគ្គនាយកដ្ឋានកស្ដុការ និងហិរញ្ញវត្ថុ*
*-អគ្គាធិការដ្ឋាន*
*-អគ្គនាយកដ្ឋានពន្ធនាគារ*
*-គ្រប់នាយកដ្ឋានចំណុះអ.រ.ប*
*"ដើម្បីជូនជ្រាប"*
*-ឯកសារ-កាលប្បវត្តិ*